E55/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 03 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម យូរ ឧត្តារ ជាប្រធាន |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម ម៉ុង មុន្នីចរិយា |
| | ចៅក្រម Katinka LAHUIS |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

---

# សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជិតចិត្ត ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
សា សូវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

# I. សេចក្ដីផ្ដើម

១. នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ បានដាក់បណ្ដឹងជំទាស់ចំពោះចៅក្រមទាំងប្រាំរូបរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ ផ្អែកតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង[1]។ បណ្ដឹងជំទាស់បានចោទប្រកាន់ថា សំអាងហេតុមួយចំនួនរបស់ចៅក្រមទាំងប្រាំរូបក្នុងសាលក្រម ឌុច[2] បណ្ដាលឱ្យមានការយល់ឃើញដោយសមហេតុផលថាមានភាពលម្អៀងនៅក្នុងការសម្រេចនាពេលអនាគតលើបញ្ហាស្រដៀងគ្នាក្នុងសំណុំរឿង ០០២។ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដី នួន ជា និង អៀង សារី បានដាក់បណ្ដឹងជំទាស់ស្រដៀងគ្នានេះដែរ[3]។ បន្ថែមពីលើនេះ បណ្ដឹងជំទាស់របស់ អៀង សារី ស្នើសុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធីក្នុងអំឡុងពេលរង់ចាំសេចក្ដីសម្រេចស្ដីពីបណ្ដឹងជំទាស់ និងស្នើសុំឱ្យបើកសវនាការស្ដាប់ដេញដោលផ្ទាល់មាត់[4]។ នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានដាក់ចម្លើយតបរួមប្រឆាំងនឹងបណ្ដឹងជំទាស់ទាំងបីនេះ[5]។ នៅថ្ងៃទី ០១ និងទី ០២ ខែ មីនា ឆ្នាំ ២០១១ មេធាវីការពារក្ដីទាំងបីក្រុមបានដាក់ចម្លើយតបទៅនឹងចម្លើយតបរួមរបស់ ក.ស.ព[6]។

---

[1] បណ្ដឹងជំទាស់របស់មេធាវីការពារក្ដី អៀង សារី ប្រឆាំងនឹងចៅក្រម និល ណុន, ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE និង ចៅក្រម យូ អ៊ុតណារ៉ា, ឯកសារ E28, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្ដឹងរបស់ អៀង ធីរិទ្ធ")។

[2] សាលក្រម សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក ឯកសារ E188 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រម ឌុច")។

[3] បណ្ដឹងជំទាស់ជាបន្ទាន់ ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង, ឯកសារ E54 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្ដឹងជំទាស់របស់ នួន ជា")។ សារណារបស់លោក អៀង សារី គាំទ្របណ្ដឹងជំទាស់របស់ អៀង ធីរិទ្ធ និង នួន ជា ចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង និង សារណារបស់ អៀង សារី ចូលរួមបណ្ដឹងរបស់ អៀង ធីរិទ្ធ ស្នើសុំដកចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដោយដាក់ជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រម បន្ថែមតាមការជ្រើសរើសរបស់គណៈកម្មាធិការរដ្ឋបាលតុលាការដើម្បីសម្រេចលើបណ្ដឹងជំទាស់ ឯកសារ E53 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្ដឹងជំទាស់ របស់ អៀង សារី")។

[4] បណ្ដឹងជំទាស់របស់ អៀង សារី, កថាខណ្ឌ ១៥-១៦។

[5] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា សុំប្ដឹងជំទាស់អង្គចៅក្រម, ឯកសារ E55, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ("ចម្លើយតប")។

[6] ចម្លើយតបរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះពី អៀង ធីរិទ្ធ, អៀង សារី និង នួន ជា, ឯកសារ E55/1, ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង ធីរិទ្ធ")។ ចម្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងជំទាស់របស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា ឯកសារ E55/2 ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១ (ចម្លើយតបរបស់ អៀង សារី)។ ចម្លើយតបចំពោះចម្លើយតបរួម

## II. សារណា

២. ក្រុមមេធាវីការពារក្ដីនីមួយៗ លើកឡើងថា សំអាងហេតុមួយចំនួន នៅក្នុងសាលក្រម ឌុច លើបញ្ហាមួយចំនួន ដែលបញ្ហាទាំងនោះក៏ទំនងជាមាននៅក្នុងសំណុំរឿងបច្ចុប្បន្នផងដែរនោះធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀង មានមន្ទិលសង្ស័យលើលទ្ធភាពនៃអង្គជំនុំជម្រះដដែលនេះ ក្នុងការវាយតម្លៃសាជាថ្មីឱ្យមានភាពយុត្តិធម៌ លើបញ្ហាទាំងនោះ នៅក្នុងបរិបទនៃសំណុំរឿង ០០២។ នៅក្នុងករណីនីមួយៗ បណ្ដឹងជំទាស់ចិត្តចោទប្រកាន់តែលើអត្ថិភាពនៃការដែលនាំឱ្យគេយល់ឃើញដោយសមហេតុផលថា មានភាពលម្អៀង ប៉ុន្តែមិនបានចោទប្រកាន់ថាចៅក្រមនៃអង្គជំនុំជម្រះកំពុងមានភាពលម្អៀងនោះទេ[7]។

៣. បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ បានកត់សម្គាល់ថា សាលក្រម ឌុច បានសម្រេចថា ជម្លោះប្រដាប់អាវុធអន្តរជាតិបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយបញ្ហានៃជម្លោះប្រដាប់អាវុធអន្តរជាតិដដែលនេះ គឺជាបញ្ហាដែលនឹងត្រូវដោះស្រាយក្នុងសំណុំរឿង០០២ ផងដែរ[8]។ មេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ បានលើកឡើងថា "វាជាការលំបាកសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចនៅក្នុងសំណុំរឿង ០០២ ថាគ្មានជម្លោះប្រដាប់អាវុធអន្តរជាតិនោះ"[9]។ បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ ក៏បានលើកឡើងដោយមិនបានបកស្រាយបន្ថែមថា មានបញ្ហាជាច្រើនទៀតនៅក្នុងសំណុំរឿង ០០២ មានភាពដូចគ្នាទៅនឹងបញ្ហាផ្សេងទៀតដែលបានសម្រេចរួចហើយនៅក្នុងរឿងក្ដី ឌុច[10]។ ទោះបីជាមានការទទួល ស្គាល់ថា តុលាការអន្តរជាតិផ្សេងទៀតបានបដិសេធចោលបណ្ដឹងជំទាស់ចិត្តដែលផ្អែកលើសេចក្ដី សម្រេចរបស់តុលាការពីមុនក៏ដោយ[11] ក៏ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ បានលើកឡើងថា ករណី នេះវាមានលក្ខណៈខុសគ្នាពីព្រោះអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរយៈពេលកម្ពុជាប្រជាធិបតេយ្យមិនត្រូវបានជំទាស់ នៅក្នុងអំឡុងពេលសវនាការជំនុំជម្រះ ឌុច

---

របស់សហព្រះរាជអាជ្ញាទៅនឹងសំណុំរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា សុំប្ដឹងជំទាស់ចិត្តចៅក្រម ឯកសារ E55/3 ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ នួន ជា")។

[7] បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៦, ៣៩។ បណ្ដឹងជំទាស់ចិត្តរបស់ នួន ជា កថាខណ្ឌ ២៦ និងបណ្ដឹងជំទាស់ចិត្តរបស់ អៀង សារី កថាខណ្ឌ ៧។

[8] បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១០, ២២-២៤។

[9] បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២៤។

[10] បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១១។

[11] បណ្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២៨-៣០, ៣៣។

នោះទេ[12]។ បណ្តឹងរបស់ អៀង ធីរិទ្ធ កត់សម្គាល់បន្ថែមថា នៅក្នុងករណីនេះ បណ្តឹងជំទាស់មិនមែនប្តឹងតែចៅក្រមមួយរូបប៉ុណ្ណោះទេ ប៉ុន្តែប្តឹងចំពោះអង្គចៅក្រមទាំងអស់របស់អង្គជំនុំជម្រះតែម្តង[13]។

៤. ក្រៅពីទឡ្ហីករណ៍ដូចគ្នានេះ បណ្តឹងជំទាស់ អៀង សារី បានបន្ថែមថា សំអាងហេតុនៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០២ ត្រូវបានយល់ដោយសមហេតុផលថា បានបង្កើតនូវភាពលម្អៀងរួចទៅហើយ ដោយសារតែសំអាងហេតុនេះ "ស្របទៅនឹង"សំអាងហេតុមួយចំនួន នៅក្នុងសាលក្រម ឌុច[14]។

៥. បណ្តឹងជំទាស់របស់ នួន ជា បានលើកឡើងនូវការយល់ឃើញផ្សេងទៀតលើទឡ្ហីករណ៍នេះ ដោយបានចោទប្រកាន់ថា ដោយសារតែវាជាផលវិបាកពីសំអាងហេតុមួយចំនួននៅក្នុងសាលក្រម ឌុច ចៅក្រមអង្គជំនុំជម្រះសាលាដំបូង "ទំនងជាបានធ្វើបុរេវិនិច្ឆ័យលើពិរុទ្ធភាពរបស់ នួន ជា"[15] រួចហើយ។ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួន បណ្តឹងជំទាស់របស់ នួន ជា បានលើកសំអាងហេតុចំនួនបីប្រភេទ ដែលត្រូវបានអះអាងជារួមថា បានបំពេញធាតុផ្សំភាគច្រើននៃបទល្មើសមួយចំនួន ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២៖ "(i) បរិបទយ៉ាងទូលំទូលាយ ឬធាតុផ្សំទូទៅ ដែលបង្កើតជាលក្ខខណ្ឌនៃការទទួលខុសត្រូវផ្នែកឧក្រិដ្ឋកម្មអន្តរជាតិ (ii) អត្ថិភាពនៃសកម្មភាពដែលត្រូវបានហាមឃាត់យ៉ាងជាក់ស្តែងនៅតាមទីតាំងពោលគឺ "ទីតាំងបទល្មើស" និង (iii)ចំណុចសំខាន់បំផុតនោះគឺថាភស្តុតាងនោះ យ៉ាងណាក៏ដោយ ត្រូវជាចំណងរវាង [នួន ជា] និងការរំលោភបំពានបែបនោះ"[16]។ មេធាវីការពារក្តីរបស់ នួន ជា បានផ្អែកសារណារបស់ខ្លួនលើរឿងក្តីចំនួនពីររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស[17]។ នៅក្នុងរឿងក្តីទាំងពីរនេះ តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សបានសម្រេចថា សំអាងហេតុនៅក្នុងសេចក្តីសម្រេចពីមុនៗលើពិរុទ្ធភាពចំពោះជនជាប់ចោទ នឹងធ្វើឱ្យមានការយល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង[18]។

---

[12] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣២។

[13] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣៥។

[14] បណ្តឹងជំទាស់របស់ អៀង សារី, កថាខណ្ឌ ៩។

[15] បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ៣៣។

[16] បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ២៧, ៣-១១។

[17] បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ១៦។

[18] រឿងក្តី *Ferrantelli and Santangelo តទល់នឹង ប្រទេសអ៊ីតាលី* សាលក្រមរបស់តុលាការ ECtHR (48/155 & 554/640) ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦ ("Ferrantelli") កថាខណ្ឌ ៥៤-៦០។ *រឿងក្តី Rojas-Morales តទល់នឹង ប្រទេសអ៊ីតាលី* សាលក្រមរបស់តុលាការ ECtHR (39676/98) ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០០ ("Rojas-Morales") កថាខណ្ឌ ៣៣-៣៥។

៦. ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញជំហរថា ខ្លួនមិនប្រើសិទ្ធិក្នុងការដាក់សារណាឆ្លើយតបផ្អែកតាមវិធាន៣៤(៧) នៃវិធានផ្ទៃក្នុងឡើយ[19]។

III. **ការពិភាក្សាសម្រេច**

៧. វិធាន ៣៤(៤)(គ) នៃវិធានផ្ទៃក្នុងចែងថា បណ្ដឹងជំទាស់ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវតែធ្វើឡើង "ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះនៅពេលសវនាការបឋម"។ ផ្ទុយមកវិញ វិធាន៣៤(៣) នៃវិធានផ្ទៃក្នុងចែងថា ការដាក់បណ្ដឹងជំទាស់ ត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន[20] នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ។ អង្គជំនុំជម្រះយល់ស្របជាមួយមេធាវីការពារក្ដី អៀង ធីរិទ្ធ និង នួន ជា ថា បណ្ដឹងជំទាស់គួរតែដាក់ឲ្យបានឆាប់រហ័ស[21]។ អង្គជំនុំជម្រះយល់ឃើញថា បណ្ដឹងជំទាស់ត្រូវបានដាក់ទាន់ពេលវេលា[22]។

ក. <u>**សំណើសុំឲ្យបើកសវនាការស្ដាប់ដោយផ្ទាល់មាត់ជាសាធារណៈ និងសុំផ្អាកដំណើរការនីតិវិធី**</u>

៨. នីតិវិធី ដែលចែងនៅក្នុងវិធាន ៣៤(៧) នៃវិធានផ្ទៃក្នុង តម្រូវឲ្យមានសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរលើបញ្ហានេះដោយផ្អែកលើបណ្ដឹងជំទាស់ និងសារណារបស់ចៅក្រមដែលត្រូវគេប្ដឹងជំទាស់ ប្រសិនបើចៅក្រមដាក់សារណាតបរបស់ខ្លួន។ វិធាននេះមិនមានចែងច្បាស់អំពីសវនាការនោះទេ ហើយច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏មិនបានតម្រូវឲ្យធ្វើយ៉ាងដូច្នេះនោះដែរ[23]។ ទាំង អ.វ.ត.ក ទាំងតុលាការអន្តរជាតិផ្សេងទៀត តែងតែសម្រេចលើបណ្ដឹងជំទាស់នេះ ដោយផ្អែកលើសារណាជា

---

[19] អនុស្សរណៈពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងជូនចំពោះគណៈកម្មាធិការរដ្ឋបាលតុលាការ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E28/1។ អនុស្សរណៈពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ជូនចំពោះប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E53/1។ អនុស្សរណៈពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងជូនចំពោះប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E54/1។

[20] បញ្ហានេះត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងវិធាន ៣៤(៤)(គ) នៃវិធានផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្មលើកទី ៧ ដែលបានអនុម័តកាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលវិធានថ្មីនេះចែងថា "បណ្ដឹងជំទាស់ប្រឆាំងនឹងចៅក្រមណាមួយរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះត្រូវតែធ្វើដាក់យ៉ាងយូរបំផុតត្រឹមពេលសវនាការបឋម"។

[21] បណ្ដឹងជំទាស់របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤។ បណ្ដឹងជំទាស់របស់ នួន ជា កថាខណ្ឌ ២៣។

[22] សេចក្ដីសម្រេចលើបណ្ដឹងរបស់លោក អៀង សារី ដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ, ឯកសារ E5/3 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ២។

[23] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥៦១ ("មិនចាំបាច់ស្ដាប់ភាគី ឬចៅក្រមពាក់ព័ន្ធនោះទេ")។

លាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[24]។ អង្គជំនុំជម្រះនឹងពិចារណាលើបញ្ហានេះឱ្យបានឆាប់រហ័សដើម្បីជាប្រយោជន៍ដល់ភាពយុត្តិធម៌។ តម្លាភាពនៃដំណើរការនីតិវិធីនឹងត្រូវបានធានាតាមរយៈការចំណាត់ថ្នាក់ឯកសារសាជាថ្មីឱ្យទៅជាឯកសារសាធារណៈទាំងអស់នូវរាល់ឯកសារនានា ដែលទាក់ទងនឹងបណ្តឹងជិតចិត្ត និងសំណើសុំ។

៩. អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង បណ្តឹងជិតចិត្តដែលរង់ចាំសេចក្តីសម្រេច មិនផ្អាកកិច្ចដំណើរការនីតិវិធីនោះទេ[25]។

## ខ. <u>ក្របខ័ណ្ឌច្បាប់</u>

១០. វិធាន ៣៤(២) នៃវិធានផ្ទៃក្នុង ចែងថា "*ភាគីអាចធ្វើបណ្តឹងជិតចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមាន*

---

[24] *សូមមើល ឧទា.* សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះចៅក្រម ន័យ ថុល ឯកសារ C11/29 ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ (សេចក្តីសម្រេចទាក់ទងនឹងចៅក្រម ន័យ ថុល") កថាខណ្ឌ៨។ សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជិតចិត្តចំពោះចៅក្រម និល ណុល និងសំណើពាក់ព័ន្ធផ្សេងៗ (សាធារណៈ) ឯកសារ E5/3 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karemera និងជនផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងជិតចិត្តរបស់ Joseph Nzirorera សុំដក Byron, Kam និង Joensen ការិយាល័យ ICTR (ICTR-98-44-T) ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin និង Talić* សេចក្តីសម្រេចលើបណ្តឹងជិតចិត្តរបស់ Momir Talić និងការសុំឱ្យដកខ្លួនរបស់ចៅក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36-PT) ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០។

[25] វិធាន៣៤(៥) នៃវិធានផ្ទៃក្នុង ចែងថា៖ ("ចៅក្រមដែលកំពុងមានបញ្ហា អាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចស្តីពីបណ្តឹងជិតចិត្ត")។ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម Katinka LAHUIS និងចៅក្រម Rowan DOWNING (សាធារណៈ)០០២/២០-១០-២០០៩-អវតក/កសចស (អបជ ០៣) ឯកសារលេខ ៥ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣ (បដិសេធចោលសំណើសុំឱ្យផ្អាកដំណើរការនីតិវិធី)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galic* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការICTY (IT-98-29-A) ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ៣៣ (ការពន្យារដំណើរការនីតិវិធីមិនមែនជាលក្ខខណ្ឌតម្រូវ សម្រាប់ការពារសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះទេ)។

ភាពលម្អៀង"។ យោងតាមវិធាន៣៤(៣) នៃវិធានផ្ទៃក្នុង បណ្តឹងជំទាស់បែបនេះ "ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និងត្រូវឱ្យមានភស្តុតាងបញ្ជាក់ផងដែរ"[26]។

១១. យុត្តិសាស្ត្ររបស់ អ.វ.ត.ក និងតុលាការអន្តរជាតិផ្សេងទៀត បានសម្រេចដោយមានភាពស៊ីសង្វាក់គ្នាថា លក្ខណៈវិនិច្ឆ័យនៃអនាគតិត្រូវបានរំលោភ មិនមែនចាំបាច់តែចៅក្រមនោះមានភាពលំអៀងជាក់ស្តែងនោះទេ គឺគ្រាន់តែស្តែងចេញឱ្យឃើញអំពីភាពលំអៀងក៏បានដែរ[27]។ ការស្តែងចេញឱ្យឃើញនូវភាពលំអៀងរួមមាន (ក) ចៅក្រមរូបនោះគឺជាភាគីណាមួយក្នុងរឿងក្តី ឬមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុចំពោះលទ្ធផលនៃរឿងក្តី ឬប្រសិនបើការសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឱ្យកើតចេញនូវបុព្វហេតុអ្វីមួយផ្សេងទៀតដែលចៅក្រមរូបនោះមានការពាក់ព័ន្ធឬ (ខ) កាលៈទេសៈទាំងនោះដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង[28]។

១២. អ្នកសង្កេតការណ៍មិនលម្អៀង ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យនេះត្រូវតែជា "បុគ្គលដែលបានទទួលព័ត៌មានគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ហើយអ្នកសង្កេតការណ៍នោះយល់ថា អនាគតិគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចនានាដែលចៅក្រមត្រូវតែប្រកាន់យកឱ្យបានខ្ជាប់ខ្ជួន"[29]។ ដូចដែលបានកត់សម្គាល់នៅក្នុងយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក ថា ចំណុចចាប់ផ្តើមនៃការ កំណត់អំពីភាពលម្អៀងរបស់ចៅក្រម គឺការសន្មតជាមុនសិនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម ដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់ជាចៅក្រមនោះ[30]។

---

[26] ផ្អែកតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បណ្តឹងជំទាស់ចំពោះចៅក្រម មានចែងនៅក្នុងមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់មូលដ្ឋានចំនួនប្រាំពីរសម្រាប់ការប្តឹងជំទាស់។ អង្គជំនុំជម្រះនឹងប្រើប្រាស់បទដ្ឋានទូលាយដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។

[27] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-17/1-A) ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Furundžija*") កថាខណ្ឌ ១៨១-១៨៨។

[28] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Furundžija* កថាខណ្ឌ ១៨៩។

[29] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Furundžija* កថាខណ្ឌ ១៩០។

[30] សេចក្តីសម្រេចរឿងក្តី ន័យ ថុល កថាខណ្ឌ ១៥-១៧។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល *Furundzija* កថា ខណ្ឌ ១៩៦ ព្រមទាំងមាត្រា ៣.៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងការកាត់សេចក្តីផ្អែកតាមច្បាប់កម្ពុជាចំពោះបទល្មើសទាំងឡាយដែលបានប្រព្រឹត្តិនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ និងមាត្រា១០ ថ្មី នៃច្បាប់ អ.វ.ត.ក។

ភាគីដែលប្តឹងជំទាស់ជំនិតមានបន្ទុកត្រូវបង្ហាញផ្ទុយពីការសន្មតទុកជាមុនបែបនេះដែលជាលក្ខខណ្ឌកម្រិតខ្ពស់តម្រូវឱ្យភាគីដាក់បណ្តឹងត្រូវបំពេញ[31]។

១៣. វាមិនមានលក្ខណៈគ្រប់គ្រាន់ទេក្នុងការចោទប្រកាន់អំពីកំហុសលើអង្គច្បាប់ណាមួយ ប្រសិនជាមានយកមកធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់អំពីភាពលម្អៀង ដោយផ្អែកលើសេចក្តីសម្រេចរបស់ចៅក្រមនោះ។ អ្វីដែលអ្នកដាក់បណ្តឹងត្រូវបង្ហាញគឺថា សេចក្តីសម្រេចពិតជាបណ្តាលឱ្យមាន ឬត្រូវបានគេយល់ឃើញដោយសមហេតុផលថាមានបុរេវិនិច្ឆ័យប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង និងជាសេចក្តីសម្រេចដែលមិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ដោយសុក្រឹត្យ ពោលគឺការបកស្រាយច្បាប់ដោយអត្តនោម័ត នៅពេលដែលច្បាប់នោះអាចបកស្រាយបានច្រើនរបៀប ឬជាសេចក្តីសម្រេចដែលមិនពិចារណាវាយតម្លៃលើអង្គហេតុពាក់ព័ន្ធនានា[32]។ ការខ្វែងគំនិតលើខ្លឹមសារនៃសេចក្តីសម្រេចគឺជាបញ្ហាសម្រាប់ការប្តឹងឧទ្ធរណ៍ មិនមែនជាបញ្ហាសម្រាប់ដាក់បណ្តឹងជំទាស់ជំនិតឡើយ[33]។

## គ. __អង្គសេចក្តី__

១៤. បណ្តឹងជំទាស់ជំនិតបានលើកឡើងបញ្ហាដែលពាក់ព័ន្ធចំនួនពីរផ្សេងគ្នា៖ (i) សំអាងហេតុរបស់តុលាការលើបញ្ហានានាក្នុងសំណុំរឿងមុនទំនងជានឹងយកមកប្រើនៅក្នុងរឿងក្តីបច្ចុប្បន្ន និង (ii) សំអាងហេតុមួយចំនួនលើជនជាប់ចោទត្រូវបានចោទប្រកាន់ថាបាននាំឱ្យមានការសន្មតពីការកំណត់ពីពិរុទ្ធភាពជាមុន ។

### *i.* *__សំអាងហេតុពីមុនលើបញ្ហារួមនានា (បណ្តឹងជំទាស់ជំនិតទាំងបី)__*

១៥. ដូចដែលតុលាការផ្សេងទៀតបានសម្រេចដោយមានភាពស៊ីសង្វាក់គ្នារួចហើយ ចៅក្រមមួយរូបមិនត្រូវបានហាមឃាត់មិនឱ្យជំនុំជម្រះលើការចោទប្រកាន់ពីបទព្រហ្មទណ្ឌពីរផ្សេងគ្នា ដែលកើតចេញពី

---

[31] សេចក្តីសម្រេចរឿងក្តី ន័យ ថុល កថាខណ្ឌ ១៥។

[32] សាលដីកាលើបណ្តឹងជំទាស់ជំនិតរបស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel LEMONDE (សាធារណៈ) សំណុំរឿងលេខ ០០២/១៣-១០-២០០៩-អវតក/អបជ(០២) ឯកសារលេខ ៧ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និងជនផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងជំទាស់ជំនិតរបស់ Blagojević ផ្អែកតាមវិធាន ១៥(ខ) ការិយាល័យ ICTY (IT-02-60) ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ១៤។

[33] សេចក្តីសម្រេចលើបណ្តឹងជំទាស់ជំនិតរបស់ ខៀវ សំផន សុំដកសហចៅក្រមស៊ើបអង្កេត Marcel Lemonde (សាធារណៈ) សំណុំរឿងលេខ ០០២/១៣-១០-២០០៩-អវតក/អបជ (០២) ឯកសារលេខ០៧ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៥។ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ជំនិត ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី/ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១១/សាធារណៈ

អង្គហេតុតែមួយនោះទេ[34] ទោះបីជារឿងក្តីទាំងពីរនេះពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ និងអង្គច្បាប់ត្រូវគ្នាក៏ដោយ។ នៅក្នុងករណីបែបនេះ "បញ្ហាមិនមែនថាតើមានការយល់ឃើញដោយសមហេតុផលដែលថា [ចៅក្រម] នឹងសម្រេចលើបញ្ហាទាំងនេះក្នុងវិធីដូចគ្នានោះទេ" ប៉ុន្តែបញ្ហាគឺនៅត្រង់ថាតើចៅក្រមនឹង "ធ្វើការសម្រេចដោយអនាគតិ និងមិនលម្អៀងក្នុងការដោះស្រាយបញ្ហានានានៅក្នុងរឿងក្តីបច្ចុប្បន្នដែរឬយ៉ាងណា"[35]។ ចំពោះសេចក្តីសម្រេចជាក់លាក់ណាមួយដែលត្រូវបានបង្ហាញតាមរយៈមតិយោបល់តាមផ្លូវតុលាការ មិនមែនជាភាពលម្អៀងនោះទេ[36]។

១៦. បញ្ហាតែមួយគត់ដែលត្រូវធ្វើការពិចារណានៅក្នុងការវិភាគនេះ គឺលទ្ធភាពរបស់ចៅក្រមក្នុងការវាយតម្លៃលើភស្តុតាងដែលនឹងត្រូវបង្ហាញនៅក្នុងរឿងក្តី*នេះ*។ គោលការណ៍ទាំងនេះនឹងត្រូវអនុវត្ត ទោះជាអវត្តមាននៃការជំទាស់ជុំវិញចំណុចជាច្រើននៃការជំនុំជម្រះក្នុងសំណុំរឿង ០០១ ក៏ដោយ។ បន្ថែមពីលើនេះ បណ្តឹងដិតចិត្តរបស់ អៀង ធីរិទ្ធ ខកខានមិនបានបង្ហាញអំពីអង្គហេតុជាក់លាក់ដែលបណ្តឹង

---

[34] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងជនផ្សេងទៀត* សេចក្តីសម្រេចលើសំណើរបស់ Sesay និង Gbao សុំឱ្យដកខ្លួនដោយស្ម័គ្រចិត្ត ឬប្តឹងដិតចិត្ត Hon។ ចៅក្រម Bankole Thompson ក្នុងរឿងក្តី RUF អង្គជំនុំជម្រះសាលដំបូង I នៃតុលាការ SCSL (SCSL-04-15-T) ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៥៥ ("អង្គហេតុដែលថា ចៅក្រមមួយរូប ជំនុំជម្រះបទល្មើសព្រហ្មទណ្ឌចំនួនពីរ ដែលកើតមានឡើងនូវព្រឹត្តិការណ៍ដូចគ្នា គឺមិនគ្រប់គ្រាន់ក្នុងការប្តឹងដិតចិត្តនោះទេ")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* ការិយាល័យ ICTY (IT-95-14/2-PT) ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ២ (ដូចគ្នា)។ *ស្របគ្នានឹង រឿងក្តី Nahimana និងជនផ្សេងទៀត តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-99-52-A) ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៧៨។

[35] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin និង Talić* សេចក្តីសម្រេចលើបណ្តឹងដិតចិត្តរបស់ Momir Talić និងការសុំឱ្យដកខ្លួនរបស់ចៅក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36-PT) ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ ("Brđanin") កថាខណ្ឌ ១៨-១៩ (បដិសេធចោលបណ្តឹងដិតចិត្ត ផ្អែកលើសំអាងហេតុពីមុនរបស់ចៅក្រមលើជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលដូចគ្នានឹងបញ្ហាដែលលើកឡើងនៅក្នុងបណ្តឹងដិតចិត្តរបស់ អៀង ធីរិទ្ធ)។ *Re Polites ex p. Hoyts Corporation Pty Ltd*, 65 AJLR 444, 448 (1991) ("វាអាចមានស្ថានភាពជាច្រើន ដែលសេចក្តីសម្រេចពីមុនរបស់មន្ត្រីតុលាការលើបញ្ហាអង្គហេតុ និងអង្គច្បាប់ អាចបង្កើតឱ្យមានការយល់ឃើញថា មន្ត្រីតុលាការរូបនោះ ទំនងជាសម្រេចលើបញ្ហានានានៅក្នុងរឿងក្តីពិសេសមួយ ផ្ទុយនឹងភាគីណាមួយនៃភាគីនានា។ ប៉ុន្តែនេះមិនមែនមានន័យថា គាត់នឹងដោះស្រាយបញ្ហានានានៅក្នុងរឿងក្តីនោះ ដោយមិនផ្អែកលើការសម្រេចអនាគតិ និងមិនលម្អៀងនោះទេ")។

[36] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karemera និងជនផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងសុំបដិសេធចោលសេចក្តីសម្រេច និងបណ្តឹងដិតចិត្តចំពោះចៅក្រម Byron និង Kim ការិយាល័យ ICTR (ICTR-98-44-T) ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ១៥ ("ដោយសារបានសម្រេចពីមុនលើបញ្ហាពាក់ព័ន្ធលើអង្គសេចក្តី លទ្ធភាពដែលថា ចៅក្រម Byron និង Kam អាចសម្រេចជាមុនក្នុងការអនុវត្តច្បាប់ និងវាយតម្លៃលើអង្គហេតុតាមរបៀបដូចគ្នានោះ គឺមិនគ្រប់គ្រាន់ថាជាបញ្ហាអង្គច្បាប់ក្នុងការដកចេញនូវការសន្មតអំពីភាពអនាគតិ")។

ជិតចិត្តនេះបានដាក់ប្រឆាំងនឹងអង្គចៅក្រមជំនុំជម្រះទាំងមូល ឬខកខានមិនបានផ្ដល់សំអាងផ្លូវច្បាប់ចំពោះអំណះអំណាងរបស់ខ្លួនដែលថា បណ្ដឹងជិតចិត្តទាំងអស់មានលក្ខណៈខុសគ្នាពីយុត្តិសាស្ត្រខាង-លើ[37]។

១៧. ដើម្បីទទួលបានជោគជ័យ បណ្ដឹងជិតចិត្តត្រូវបង្ហាញភស្តុតាងអំពីការយល់ឃើញដោយសមហេតុផលថា ចៅក្រមពិតជានឹងមិនធ្វើការវាយតម្លៃលើបញ្ហានានានៅក្នុងសំណុំរឿង ០០២ ប្រកបដោយភាពអនាគតិ។ ការគ្រាន់តែអះអាងថា ចៅក្រមនឹងមាន "ការពិបាក និងរារែក" ក្នុងការចេញសេចក្ដីសម្រេចដែលមិនស្របគ្នានឹងសាលក្រម ឌុច គឺមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវបទដ្ឋាននោះទេ[38]។ ចៅក្រមនៅ អ.វ.ត.ក មានលក្ខណៈសម្បត្តិខ្ពស់ និងជាអ្នកច្បាប់មានបទពិសោធន៍ដែលមានជំនាញលើច្បាប់សារធាតុដែលកំពុងតវ៉ានេះ[39]។ អ្នកសង្កេតការណ៍មិនលម្អៀង ដែលវាយតម្លៃលើកាលៈទេសៈពាក់ព័ន្ធទាំងអស់មិនធ្វើការសន្និដ្ឋានសើៗថាចៅក្រមនឹងជួបនូវការ "រារែក" ដោយសារការអនុវត្តតួនាទីត្រឹមត្រូវតាមផ្លូវតុលាការនោះ។

១៨. ស្រដៀងគ្នានេះដែរ ការដែលអង្គជំនុំជម្រះបានយល់ឃើញលើបញ្ហាមួយចំនួននៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តដែលបានដាក់នៅក្នុងសំណុំរឿង ០០២ មានលក្ខណៈ "ស្របគ្នាជាមួយ" ចំណុចនានានៃសាលក្រមឌុច មិនអាចចាត់ទុកថាមានភាពលម្អៀងនោះទេ[40]។ នៅក្នុងសាលក្រម ឌុច មានការបង្ហាញសំអាងហេតុជាទូទៅថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ "មិនមាននូវដំណើរការនៃប្រព័ន្ធតុលាការ"[41]។ នៅក្នុងសេចក្ដីសម្រេចសំណុំរឿង០០២ អង្គជំនុំជម្រះបានយល់ឃើញថា ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជានៅមាន "ភាពទន់ខ្សោយចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យ" ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់អំពីកង្វះឯករាជ្យភាពប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[42]។

---

[37] បណ្ដឹងជិតចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣៤។

[38] បណ្ដឹងជិតចិត្តរបស់ អៀង ធីរិទ្ធ កថាខណ្ឌ២៤។

[39] សូមមើលជើងទំព័រ ៣១ ខាងលើ។ *រឿងក្ដី Nahimana និងជនផ្សេងទៀត តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-99-52-A) ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៧៨ ("នៅក្នុងករណីអវត្តមានភស្តុតាងក្នុងការជំទាស់វាត្រូវបានសន្និដ្ឋានថា ផ្អែកតាមការបណ្ដុះបណ្ដាល និងបទពិសោធន៍ ចៅក្រមនឹងសម្រេចដោយយុត្តិធម៌លើបញ្ហានានា ដោយផ្អែកទាំងស្រុងនិងដាច់ដោយឡែកលើភស្តុតាងដែលបានបង្ហាញនៅក្នុងរឿងក្ដីនោះ")។

[40] បណ្ដឹងជិតចិត្តរបស់ អៀង សារី កថាខណ្ឌ៩។

[41] សាលក្រម ឌុច កថាខណ្ឌ ៩៤។

[42] សេចក្ដីសម្រេចលើបណ្ដឹងរបស់លោក អៀង សារី ដែលប្ដឹងជិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ (សាធារណៈ) ឯកសារ E5/3 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ១៣។

បើទោះបីជាទូទៅ វាពាក់ព័ន្ធទៅនឹងប្រធានតែមួយមែនក៏ដោយ ក៏ការយល់ឃើញទាំងនោះមានលក្ខណៈខុសគ្នា និងបានកើតឡើងនៅក្នុងបរិបទផ្សេងៗគ្នា។ បន្ថែមពីលើនេះ នៅក្នុងសេចក្តីសម្រេចសំណុំរឿង០០២ មិនមានការនិយាយយោងទៅដល់សាលក្រមឌុចទេ ហើយការយល់ឃើញគឺធ្វើឡើងដោយផ្អែកលើការពិចារណាដាច់ដោយឡែកពីគ្នាទៅលើភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ។

១៩. តាមរយៈការលើកឡើងដោយគ្មានភស្តុតាងពិតប្រាកដ បណ្តឹងជិតចិត្តមិនបានបង្ហាញអំពីការយល់ឃើញដោយសមហេតុផលថា មានភាពលម្អៀងលើបញ្ហារួមនៅក្នុងសំណុំរឿង០០២ និងសាលក្រមឌុច នោះទេ។

*ii. ការសម្រេចជាមុនលើពិរុទ្ធភាព (បណ្តឹងជិតចិត្តរបស់ នួន ជា)*

២០. ថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានទទួលស្គាល់លទ្ធភាពដែលថា "ការសម្រេចពីពេលមុនលើពិរុទ្ធភាពរបស់បុគ្គលម្នាក់" អាចបង្ហាញនូវការយល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង[43]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះដែលមានសមាសភាពដដែលនេះ បានធ្វើសវនាការលើរឿងក្តីជាបន្តបន្ទាប់ក្រោយៗមកទៀតហើយបានសម្រេចថា ការសម្រេចពីពេលមុនតែមួយមិនមែនជាភាពលម្អៀង ដែលអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ប្តឹងជិតចិត្តនោះឡើយ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ប្រភេទយុត្តាធិការខុសគ្នានៅក្នុងលំដាប់តែមួយដែលអនុវត្តការជំនុំជម្រះលើអង្គហេតុតែមួយអាចនឹងនាំមកនូវលទ្ធផលខុសគ្នា[44]។ ដោយផ្អែកលើកាលៈ-

[43] *រឿងក្តី Ntawukulilyayo តទល់នឹង រដ្ឋអាជ្ញា* សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចំពោះចៅក្រម អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-05-82-A) ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karadzic* សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចំពោះចៅក្រម Picard និងរបាយការណ៍ជូនចំពោះអនុប្រធាន អនុលោម តាមវិធាន ១៥(ខ)(ii) តុលាការICTY (IT-95-05/18-PT) ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ២២ (មតិយោបល់ពីមុន មិនមែន "ជាសំអាងហេតុពិតប្រាកដ ឬសន្និដ្ឋានថាជាសំអាងហេតុលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល" របស់ជនជាប់ចោទ)។

[44] *រឿងក្តី Nahimana និងជនផ្សេងទៀត តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-99-52-A) ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ៧៨។ *រឿងក្តី Karera តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-01-74-A) ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៧៨ ("ចៅក្រមនៃតុលាការនេះពេលខ្លះពាក់ព័ន្ធនឹងការជំនុំជម្រះ ដែលបញ្ហាមួយចំនួនមានលក្ខណៈត្រួតគ្នា")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* ការិយាល័យ ICTY (IT-95-14/2-PT) ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ២-៣ ("ប្រភេទនៃយុត្តាធិការរបស់តុលាការ គឺក្នុងថាសំណុំរឿងនៅចំពោះមុខអង្គជំនុំជម្រះមិនអាចជៀសផុតពីការត្រួតគ្នានោះទេ។ ម្យ៉ាងវិញទៀត បញ្ហាដូចគ្នា និងភស្តុតាងដូចគ្នា គឺតែងតែមានភាពពាក់ព័ន្ធ។ មួយវិញទៀត តុលាការមានចំនួនកំណត់នៃចៅក្រម។ បើយកតាមទស្សនៈផ្ទុយដែលតម្រូវឲ្យមានចៅក្រមផ្សេងទៀតសម្រេចលើរឿងក្តីនេះ ការងាររបស់តុលាការនឹងត្រូវជាប់គាំងជាមិនខាន")។

ទេសៈនេះ អ្នកសង្កេតការណ៍មិនលម្អៀងយល់ថា ចៅក្រមនៅក្នុងតុលាការបែបនេះដែលបានបង្ហាញសំអាងហេតុទៅលើរឿងក្តីមួយដែលផ្អែកលើសារតា និងបរិបទនៃរឿងក្តីផ្សេងទៀតនោះ មិនធ្វើឱ្យមានភាពសង្ស័យទៅលើភាពអនាគតិនៃតុលាការនេះឡើយ។

២១. ដូចគ្នានេះដែរ មេធាវីការពារក្តីរបស់ នួន ជា បានយោងទៅលើសំអាងរបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សដែលបានសម្រេចថា ចៅក្រមត្រូវបានអនុញ្ញាតឱ្យជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌពីរដែលមានអង្គហេតុដូចគ្នាបាន[45] តែក្នុងករណីដែលការសម្រេចពីពេលមុនរបស់តុលាការនេះ "ពិតជាមិនបានធ្វើបុរេវិនិច្ឆ័យ" លើពិរុទ្ធភាពរបស់ជនជាប់ចោទ[46]។ ការសន្និដ្ឋានបែបនេះ រួមមានការសម្រេចនៅក្នុងមតិយោបល់ជាមុន "ចំពោះលក្ខណៈវិនិច្ឆ័យចាំបាច់ពាក់ព័ន្ធទាំងអស់ក្នុងការបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ និង ... ថាតើអ្នកដាក់ពាក្យសុំមានពិរុទ្ធភាពលើសពីវិមតិសង្ស័យចំពោះការប្រព្រឹត្តិបទល្មើសបែបនេះ" ដែរ ឬយ៉ាងណា[47]។ ដូចនេះ នៅក្នុងករណីនានាដែលបណ្តឹងជំទាស់របស់ នួន ជា បានយកមកជាសំអាងនោះ សេចក្តីសម្រេចពីមុនពិតជាបានរកឃើញអំពីតួនាទីសកម្មរបស់ដើមបណ្តឹងដែលក្រោយមកដើមបណ្តឹងទាំងនោះត្រូវបានផ្តន្ទាទោសចំពោះការប្រព្រឹត្តបទល្មើសនោះ[48]។ យុត្តិសាស្ត្ររបស់តុលាការ ECHR ក៏បានលើកឡើងថា នៅពេលតុលាការយល់ថា ដរាបណាខ្លួនមិនបានប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទទេនោះ តុលាការក៏មិនត្រូវបានចាត់ទុកថាបានបង្កើតឱ្យមាននូវភាពលម្អៀងដែរ[49]។

២២. បណ្តឹងជំទាស់របស់ នួន ជា បានកំណត់នូវកថាខណ្ឌចំនួនបីនៅក្នុងសាលក្រមឌុច ដែលជាសំអាងហេតុពាក់ព័ន្ធជាពិសេសចំពោះ នួន ជា ពោលគឺនៅពេលសំអាងហេតុទាំងនោះគួបផ្សំជាមួយនឹងផ្នែកផ្សេងៗទៀតនៃសាលក្រម វាបង្កើតបានជាបុរេវិនិច្ឆ័យថា នួន ជា ពិតជាមានពិរុទ្ធភាព។ ទីមួយ បណ្តឹងជំទាស់របស់ នួន ជា បានអះអាងថា សាលក្រម ឌុច "បានរៀបរាប់អំពីវិធីដែល ឌុច ... "បាន

---

[45] *រឿងក្តី Poppe តទល់នឹង ប្រទេសហូឡង់* សាលក្រមរបស់តុលាការECHR (32271/04) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ("រឿងក្តី Poppe") កថាខណ្ឌ ២៦។ *រឿងក្តី Schwarzenberger តទល់នឹង ប្រទេសអាល្លឺម៉ង់* សាលក្រមរបស់តុលាការECHR (75737/01) ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៦ ("រឿងក្តី Schwarzenberger") កថាខណ្ឌ ៤២។ ទាំង ក្នុងរឿងក្តី Poppe និងរឿងក្តី Schwarzenberger បានពិចារណា និងបដិសេធបណ្តឹងជំទាស់របស់ *Ferrantelli និង Rojas-Morales* ដែលមេធាវីការពារក្តី នួន ជា ដកស្រង់យុត្តិសាស្ត្រនេះ។

[46] *រឿងក្តី Poppe* កថាខណ្ឌ ២៦។

[47] *រឿងក្តី Poppe* កថាខណ្ឌ ២៨។

[48] *រឿងក្តី Ferrantelli* កថាខណ្ឌ ៥៩។ *Rojas-Morales* កថាខណ្ឌ ៣៣។

[49] *រឿងក្តី Schwarzenberger* កថាខណ្ឌ ៤៣។

00655713



ទទួលការណែនាំពី សុន សេន ដែលជាថ្នាក់លើរបស់គាត់ និងក្រោយមក នួន ជា”[50]។ ជាការពិត ប្រយោគទាំងនេះបានចាប់ផ្តើមជាមួយនឹងឃ្លាថា “អនុលោមតាមសក្ខីកម្ម [របស់ឌុច]” ពោលគឺមិនបានលើកមកធ្វើជាសំអាងហេតុឡើយ[51]។ កថាខណ្ឌផ្សេងជាច្រើនទៀត ដែលលើកឡើងនៅក្នុងជើងទំព័រនៃបណ្តឹងមិនតចិត្តក៏មិនបានបង្ហាញអំពីការយល់ឃើញអង្គជំនុំជម្រះដែរ[52]។ ការលើកឡើងបែបនេះមិនអាចបង្កើតបានជាមូលដ្ឋានសម្រាប់សាលក្រមមួយដែលដាក់ពិរុទ្ធភាពឡើយ។ ហេតុដូច្នេះ មិនអាចគាំទ្រដល់ការចោទប្រកាន់អំពីការយល់ឃើញដោយសមហេតុផលថា មានភាពលម្អៀងបានទេ។

២៣. កថាខណ្ឌពីរផ្សេងទៀតនៅក្នុងសាលក្រមឌុចដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងរបស់ នួន ជា មានសំអាងហេតុតិចតួចប៉ុណ្ណោះដែលពាក់ព័ន្ធនឹង នួន ជា។ កថាខណ្ឌ៨៥ លើកឡើងថា នួន ជា គឺជាអនុលេខារបស់ ប៉ុល ពត ជាអង្គហេតុមួយដែលមេធាវីរបស់ នួន ជា ទទួលស្គាល់[53] និងថាគាត់គឺជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា។ កថាខណ្ឌ៩៥ លើកឡើងថា នួន ជា គឺជាសមាជិកគណៈយោធានៃបក្សកុម្មុយនីស្តកម្ពុជា និងនៅចំណុចខ្លះថា ជាថ្នាក់លើរបស់ឌុច។ យោងតាម នួន ជា សំអាងហេតុទាំងនោះបង្ហាញពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់គាត់ចំពោះបទឧក្រិដ្ឋជាច្រើនដែលត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ដើម្បីផ្តន្ទាទោស ឌុច តាមរយៈទម្រង់នៃការទទួលខុសត្រូវបីខុសគ្នាគឺ សហឧក្រិដ្ឋកម្មរួម ការបញ្ជា និងការទទួលខុសត្រូវរបស់ថ្នាក់លើ[54]។

២៤. អង្គជំនុំជម្រះកត់សម្គាល់ថា សំអាងហេតុនៅក្នុងកថាខណ្ឌ ៨៥ និង៩៥ នៃសាលក្រមឌុច និយាយតែអំពីតួនាទីផ្លូវការរបស់ នួន ជា នៅក្នុងឋានានុក្រមនៃរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជាហើយអង្គជំនុំជម្រះយល់ថាការរកឃើញបែបនេះមិនបានបង្ហាញនូវ*អំពើពិរុទ្ធ* ឬ ធាតុផ្សំសត្យានុម័តនៃទម្រង់ណាមួយនៃការទទួលខុសត្រូវទាំងបីឡើយ[55]។ ជាងនេះទៅទៀត ទម្រង់សហឧក្រិដ្ឋកម្មរួមនីមួយៗ ការបញ្ជាជនម្នាក់ទៀតឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងការទទួលខុសត្រូវរួមបន្ថែមទៀតនោះ តម្រូវឲ្យមាន

[50] បណ្តឹងមិនតចិត្តរបស់ នួន ជា កថាខណ្ឌ ១០(ខ)។

[51] សាលក្រម ឌុច កថាខណ្ឌ ៩០។

[52] *សូមមើល* បណ្តឹងមិនតចិត្តរបស់ នួន ជា ជើងទំព័រ៩៤ ដកស្រង់សាលក្រម ឌុច កថាខណ្ឌ ១០៩, ១៣១, ១៦៦ និង១៧០។

[53] បណ្តឹងមិនតចិត្តរបស់ នួន ជា កថាខណ្ឌ១១។

[54] បណ្តឹងមិនតចិត្តរបស់ នួន ជា កថាខណ្ឌ ៣០-៣២។

[55] សាលក្រម ឌុច កថាខណ្ឌ ៥០៨, ៥២៧, ៥៣៨។

ភស្តុតាងបង្ហាញពីធាតុចេតនា។ សាលក្រមរបស់ ឌុច មិនបានធ្វើការវិនិច្ឆ័យថា នួន ជា មានចេតនាឧក្រិដ្ឋទេ។ ហេតុដូច្នេះ មិនអាចមានហេតុផលថា សាលក្រមនេះឆ្លុះបញ្ចាំងពីពិរុទ្ធភាពរបស់ នួន ជា ឡើយ។

២៥. សំអាងហេតុនោះត្រូវបានគាំទ្រដោយយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានបដិសេធទឡ្ហីករណ៍ដូចគ្នាដោយផ្អែកទៅលើសំអាងហេតុជាមូលដ្ឋានអំពីតួនាទីរបស់ជនជាប់ចោទ[56]។ រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាចំណុចសំខាន់នៅក្នុងការជំនុំជម្រះ ឌុច[57] ហើយសំអាងហេតុទាំងអស់ពឹងផ្អែកទៅលើភស្តុតាង និងគាំទ្រដោយឯកសារយោងនៅចំពោះមុខអង្គជំនុំជម្រះ។ គ្មានសំអាងហេតុណាមួយនៃសំអាងហេតុទាំងនេះបង្កើតបានជាការកំណត់អំពីពិរុទ្ធភាព និងលុបបំបាត់នូវសច្ចធារណ៍និរទោស ដែលនៅតែបន្តអនុវត្តចំពោះជនជាប់ចោទផ្សេងទៀត នៅចំពោះមុខអង្គជំនុំជម្រះនៃ អ.វ.ត.ក[58] នោះទេ។

## ហេតុដូច្នេះសម្រេច

**បដិសេធ** សំណើសុំឱ្យបើកសវនាការជាសាធារណៈ។

**បដិសេធ** បណ្តឹងជំទាស់។

ផ្អែកតាមវិធាន៣៤(៨) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

---

[56] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karadzic* សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម Picard និងរបាយការណ៍ជូនចំពោះអនុប្រធាន អនុលោមតាមវិធាន ១៥(ខ)(ii) តុលាការICTY (IT-95-05/18-PT) ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ២១ (តួនាទីចុងចោទក្នុងនាមជាប្រធានរដ្ឋាភិបាល ដែលភ្នាក់ងាររបស់ខ្លួន ត្រូវបានសម្រេចឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ មិនបានបង្កន័យដោយស្វ័យប្រវត្តិអំពីការឃើញពិរុទ្ធភាពរបស់ចុងចោទនោះទេ ដោយសារតែការទទួលខុសត្រូវរបស់ថ្នាក់លើ តម្រូវឱ្យបង្ហាញភស្តុតាងអំពីការដឹង)។ *Nahimana និងជនផ្សេងទៀត តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-99-52-A) ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ៨៣-៨៤ (សំអាងហេតុពីមុនដែលជនជាប់ចោទគឺជាប្រធានអង្គការដែលបានញុះញង់ឱ្យមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនបានដកចេញនូវការសន្មតជាមុននៃភាពអនាគតិនោះទេ)។ *រឿងក្តី Poppe* កថាខណ្ឌ ២៨ (ការដែលថា ដើមបណ្តឹងដែលត្រូវបានរៀបរាប់ថាជា "បុគ្គលសំខាន់" នៃការរៀបចំបទល្មើសព្រហ្មទណ្ឌ គឺមិនគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមានភាពលម្អៀងនោះទេ)។

[57] *រឿងក្តី Schwarzenberger* កថាខណ្ឌ ៤៤ (កត់សម្គាល់ថា សេចក្តីថ្លែងដែលត្រូវបានជំទាស់ គឺ "ពាក់ព័ន្ធនឹងការផ្តន្ទាទោស D")។

[58] វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ មាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក។

យូរ ឧត្តារា

Claudia FENZ

ម៉ុង មុន្នីចរិយា

Katinka LAHUIS

ហួត វុឌ្ឍី